**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៦. អនក្រ. បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានអគិបឡង់អាស៊ីសចុះ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក ញ៉ែម សចុះ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ១៨៤២ អយក.ឧស ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥

**ស ម្រេ ច**

**មាត្រា ១ :** ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចះ SACHAK ASIA DEVELOPMENT INSTITUTE ហៅកាត់ជាភាសាខ្មែរ វ.អ.អ.ស. និងហៅកាត់ជាភាសាអង់គ្លេស SADI ។

**មាត្រា ២ :** វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចះ មានទីតាំងស្ថិតនៅផ្ទះលេខ ៦៤ ផ្លូវលេខ ៣៤៨ សង្កាត់ ទួលស្វាយព្រៃទី ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣ :** វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចះ ធ្វើការបណ្តុះបណ្តាលកម្រិត :

- បរិញ្ញាបត្ររង សិក្សារយៈពេល ២ឆ្នាំ ជាមធ្យម
- បរិញ្ញាបត្រ សិក្សារយៈពេល ៤ឆ្នាំ ជាមធ្យម

វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពី ក្រសួងអប់រំ យុវជននិងកីឡា។

**មាត្រា ៤ :** វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចះ មានមហាវិទ្យាល័យចំនួន ០៣ :

- មហាវិទ្យាល័យភាសាបរទេស : មានឯកទេស ការអប់រំភាសាអង់គ្លេស និង ភាសាអង់គ្លេស
- មហាវិទ្យាល័យគ្រប់គ្រង : មានឯកទេសគ្រប់គ្រងពាណិជ្ជកម្ម ទីផ្សារ គណនេយ្យ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យព័ត៌មានវិទ្យា : មានឯកទេស វិទ្យាសាស្ត្រកុំព្យូទ័រ។

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យ ឯកទេស ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥ :** វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចះ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

**មាត្រា ៦ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃវិទ្យាស្ថាន ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន និងមានការឯកភាពពី ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៧ :** វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចះ ត្រូវគោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាលរបស់ ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ។

**មាត្រា ៨ :** នាយកនៃវិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចះ មានភារកិច្ចទទួលខុសត្រូវ នៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ធានាឱ្យបាននូវសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សាជូននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៩ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់ វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចះ និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាម កម្រិត និងតាមឯកទេស ដែល

បានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចូៈ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចូៈ បានបំពេញ និងអនុវត្តតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ១០ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងវិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចូៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

ភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១០
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ